ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៥២ សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០

# ប្រកាស
## ស្ដីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញអនុក្រឹត្យ លេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ -**

ត្រូវបានបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១ - | ឯកឧត្តម | គង់ វិបុល | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាប្រធាន |
| ២ - | ឯកឧត្តម | អឿ ហ៊ុនលី | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធានប្រចាំការ |
| ៣ - | លោក | យុត សាខន | ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៤ - | លោក | អៀង ស៊ុនលី | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច | ជាអនុប្រធាន |
| ៥ - | លោក | សុខ សារ៉ាវុឌ្ឍ | ប្រធាននាយកដ្ឋានថវិកា | ជាអនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៦ - | លោក | យក់ ប៊ុណ្ណា | ប្រធាននាយកដ្ឋានបុគ្គលិក | ជាសមាជិកអចិន្ត្រៃយ៍ |
| ៧ - | ឯកឧត្តម | ង៉ិន យន | អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ | ជាសមាជិក |
| ៨ - | ឯកឧត្តម | ស៊ឹម អៀង | អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | ជាសមាជិក |
| ៩ - | ឯកឧត្តម | ប៉ែន ស៊ីម៉ន | អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករ | ជាសមាជិក |
| ១០ - | លោក | គឹម ផល្លា | ប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ | ជាសមាជិក |
| ១១ - | លោក | ហ៊ែល ចំរើន | ប្រធាននាយកដ្ឋាននីតិកម្ម | ជាសមាជិក |
| ១២ - | លោក | សេង ស្រេង | នាយកវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ១៣ - | លោក | អូន ប៊ុនហាក់ | ប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | ជាសមាជិក |
| ១៤ - | លោក | នេត មុន្នី | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | ជាសមាជិក |
| ១៥ - | លោក | ឈឹម សារ៉េត | ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ | ជាសមាជិក |
| ១៦ - | លោក | អ៊ុយ សម្បត្តិ | ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន | ជាសមាជិក |
| ១៧ - | លោក | ចាន់ សុធី | ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ | ជាសមាជិក |
| ១៨ - | លោក | ម៉ី វ៉ាន់ | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | ជាសមាជិក |
| ១៩ - | លោក | ផាន់ ផល្លា | ប្រធាននាយកដ្ឋានពត៌មានវិទ្យា | ជាសមាជិក |
| ២០ - | លោក | ឈន សុភាព | ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ | ជាសមាជិក |
| ២១ - | លោក | លីវ ប៊ុនហៃ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | ជាសមាជិក |
| ២២ - | លោក | ជា វុធណា | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | ជាសមាជិក |
| ២៣ - | លោក | ឯក វិរៈវឌ្ឍ | អគ្គាធិការនៃអគ្គាធិការដ្ឋាន | ជាសមាជិក |

**ប្រការ ២-**

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានភារកិច្ច ដូចតទៅ ៖

- ជាសេនាធិការជួយដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍នៅក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តរាល់សេចក្តីសម្រេចចិត្តរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផ្សព្វផ្សាយ អប់រំដល់មន្ត្រីរាជការទាំងអស់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីកិច្ចការពារនិងប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនទៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

**ប្រការ ៣-**

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតក្រុមការងារប្រយុទ្ធនឹងជំងឺអេដស៍នៅតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤-**

អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាពទាំងអស់ក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម អស់លោក ដែលមានរាយនាមនៅក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ។

**ប្រការ ៥-**

សេចក្តីប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូនៈ

-អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព

ចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាមីខ្លួន ដែលមានរាយដូចក្នុងប្រការ១

-ឯកសារ